# បណ្តាញ OR PTC DCI Mobile App Offline

### តើអ្វីទៅជាបណ្តាញ Mobile App Offline?

Mobile App Offline អាចឱ្យអ្នក ដែលជាអ្នកផ្តល់សេវា បង្កើតព័ត៌មានបញ្ចូលចំនួនរហូតដល់ 10 នៅក្នុងកម្មវិធី OR PTC DCI Mobile App រយៈពេលរហូតដល់ 5 ថ្ងៃជាប់ៗគ្នា ដោយពុំចាំបាច់ភ្ជាប់ជាមួយសេវាទូរស័ព្ទ ឬបណ្តាញ WiFi ឡើយ។

### តើខ្ញុំចាប់ផ្តើមជាមួយ Mobile App Offline បានយ៉ាងដូចម្តេច?

អ្នកនឹងត្រូវការទិន្នន័យសេវាទូរស័ព្ទ ឬ WiFi ដើម្បីចាប់ផ្តើម។ លើកដំបូងដែលអ្នកចូលកម្មវិធី OR PTC DCI ពីឧបករណ៍ចល័ត (ដូចជាថេប្លេត ឬស្មាតហ្វូន) ពេលភ្ជាប់អ៊ីនធឺណិត នោះកម្មវិធី OR PTC DCI នឹងចុះឈ្មោះឧបករណ៍របស់អ្នកដោយស្វ័យប្រវត្តិ។ អ្នកត្រូវតែប្រើឧបករណ៍នេះសម្រាប់ Mobile App Offline ដើម្បីដំណើរការ។

### តើខ្ញុំអាចចុះឈ្មោះឧបករណ៍លើសពីមួយសម្រាប់បណ្តាញ Mobile App Offline?

បណ្តាញ Mobile App Offline នឹងដំណើរការតែពីឧបករណ៍ដែលបានចុះឈ្មោះតែមួយរបស់អ្នកប៉ុណ្ណោះ។ អ្នកអាចចុះឈ្មោះឧបករណ៍បានតែមួយប៉ុណ្ណោះ ហើយឧបករណ៍មួយអាចចុះឈ្មោះសម្រាប់តែអ្នកប្រើប្រាស់ម្នាក់ប៉ុណ្ណោះ។ ប្រសិនបើអ្នកត្រូវការផ្លាស់ប្តូរឧបករណ៍ដែលបានចុះឈ្មោះរួចហើយ សូមទាក់ទងការិយាល័យក្នុងតំបន់របស់អ្នកដើម្បីស្នើសុំជំនួយ។

### ឧបករណ៍របស់ខ្ញុំត្រូវបានចុះឈ្មោះរួចហើយ។ តើត្រូវធ្វើអ្វីទៀត?

នៅពេលអ្នកចូលក្នុងកម្មវិធី OR PTC DCI Mobile App កម្មវិធី mobile app នឹងពិនិត្យមើលការភ្ជាប់បណ្តាញអ៊ីនធឺណិតរបស់អ្នក។ ប្រសិនបើពុំមានសេវាអ៊ីនធឺណិតទេ នោះកម្មវិធី mobile app នឹងប្តូរទៅបណ្តាញ Mobile App Offline ដោយស្វ័យប្រវត្តិ។ ផ្ទាំង "Offline" នឹងបង្ហាញពេញផ្នែកខាងលើនៃអេក្រង់ Mobile App នៅពេលវាស្ថិតនៅ offline។ ផ្ទាំងព័ត៌មានរបស់អ្នកនឹងបង្ហាញប៊ូតុង Clock In។ រាល់មុខងារ និងព័ត៌មានផ្សេងៗទៀត។ រាល់មុខងារ និងព័ត៌មានទាំងអស់ផ្សេងទៀតពុំទាន់មាននៅឡើយទេ។



**តើខ្ញុំអាចធ្វើអ្វីខ្លះនៅក្នុងបណ្តាញ Mobile App Offline?**
អ្នក ក្នុងនាមជាអ្នកផ្តល់សេវា អាចដាក់ម៉ោងចូល និងម៉ោងចេញនៅក្នុងបណ្តាញ Mobile App Offline។ ដំណើរការនេះរួមមាន៖

- ការចូលទៅក្នុងកម្មវិធី OR PTC DCI Mobile App
- ការជ្រើសរើសដាក់ម៉ោងចូល (Clock In)
- ការជ្រើសរើសដាក់ម៉ោងចេញ (Clock Out)
- ការបញ្ចប់ការផ្ទៀងផ្ទាត់ម៉ោងចេញ (clock out)
- ការបន្ថែមកំណត់សម្គាល់ និងភារកិច្ចនៅក្នុងពេលដាក់ម៉ោងចេញ
- ការចាកចេញពីកម្មវិធី OR PTC DCI Mobile App

ដើម្បីការពារសុវត្ថិភាព ព័ត៌មានមួយចំនួននឹងត្រូវកាត់បន្ថយ ឬទុកឱ្យនៅទទេ។ អ្នកនឹងមើលឃើញតែនាមត្រកូល និងនាមខ្លួនរបស់អ្នកប្រើប្រាស់តែប៉ុណ្ណោះ។ អ្នកនឹងមិនអាចមើលឃើញសមតុល្យនៃសេចក្តីអនុញ្ញាតឡើយ (ចំនួនម៉ោងនៅសល់នៅក្នុងសេវាដែលបានផ្តល់ជូន)។




**តើខ្ញុំដាក់ម៉ោងចូល និងម៉ោងចេញនៅក្នុងបណ្តាញ Mobile App Offline យ៉ាងដូចម្តេច?**
គ្មានការផ្លាស់ប្តូរណាមួយទៅលើរបៀបដែលអ្នកដាក់ម៉ោងចូល និងម៉ោងចេញឡើយ នៅក្នុងបណ្តាញ Mobile App Offline។ សូមអនុវត្តតាមដំណាក់កាលធម្មតាដើម្បីបញ្ចូលម៉ោង។

**តើខ្ញុំអាច offline បានរយៈពេលប៉ុន្មាន?**
ឧបករណ៍អាច offline បានត្រឹមតែរយៈពេល 5 ថ្ងៃជាប់ៗគ្នាប៉ុណ្ណោះ។
អ្នកអាចធ្វើការបញ្ចូលព័ត៌មាន offline ចំនួនរហូតដល់ 10 ដង មុនពេលត្រឡប់ទៅ online ឡើងវិញ។ ប្រសិនបើអ្នកoffline រយៈពេលលើសពី 5 ថ្ងៃ ឬព្យាយាមធ្វើការបញ្ចូលលើសពី 10 ដង

នោះអ្នកនឹងទទួលបានសារថា
“អ្នកបានលើសកម្រិតកំណត់ក្នុងការបន្ថែមព័ត៌មានបញ្ចូលព័ត៌មាន offline”។

សូមចុច Confirm នៅលើផ្ទាំងសារជូនដំណឹង (Alert)៖




ទាល់តែចូលកម្មវិធី OR PTC DCI mobile app នៅពេលឧបករណ៍ភ្ជាប់ជាមួយអ៊ីនធឺណិត ទើបអ្នកអាចដាក់ម៉ោងចូលម្តងទៀត។

**តើមានអ្វីកើតឡើងនៅពេលខ្ញុំចូលកម្មវិធី mobile app នៅពេលខ្ញុំត្រឡប់ទៅ online វិញ?**
ព័ត៌មានបញ្ចូលរបស់អ្នកនឹងត្រូវរក្សាទុកនៅក្នុងកម្មវិធី Mobile App នៅពេល offline។ នៅពេលឧបករណ៍របស់អ្នកត្រឡប់ទៅ online វិញ អ្នកនឹងទទួលបានសារជូនដំណឹងថា៖ “You are back online. Please click on confirm to synchronize your data (អ្នកបានត្រឡប់ទៅ online។ សូមចុចលើ confirm ដើម្បីរៀបទិន្នន័យរបស់អ្នក)”។

សូមចុច confirm នៅលើផ្ទាំងសារជូនដំណឹងដើម្បីបញ្ចូលព័ត៌មាន
របស់អ្នកទៅក្នុងកម្មវិធី OR PTC DCI៖



នៅពេលអង្គភាពរបស់អ្នកកំពុងបញ្ជូលទិន្នន័យ អ្នកនឹងមើលឃើញសារៈ “ទិន្នន័យ offline របស់អ្នកកំពុងរៀបចំ។ សូមកុំផ្តាច់អ៊ីនធឺណិត ឬបិទកម្មវិធី បើមិនដូច្នោះទេទិន្នន័យរបស់អ្នកនឹងត្រូវបាត់បង់”។




ព័ត៌មានរបស់អ្នកត្រូវការពេលមួយចំនួនដើម្បីបញ្ជូល។ នៅពេលចប់រួចរាល់ ទិន្នន័យរបស់អ្នកនឹងបង្ហាញនៅក្នុងផ្ទាំង Entries នៅក្នុងម៉ឺនុយរបស់អ្នក។

***សារសំខាន់៖*** ទិន្នន័យរបស់អ្នកត្រូវដាក់ចូលក្នុងកម្មវិធី OR PTC DCI ដើម្បីធ្វើការទូទាត់។ អ្នកត្រូវបញ្ជូលទិន្នន័យរបស់អ្នកនៅមុនពេលបញ្ចប់រយៈពេលអនុគ្រោះរបស់អ្នកនៅក្នុងអនុស្សរណៈញ្ញារួម (Collective Bargaining Agreement) ដែលត្រូវទូទាត់នៅក្នុងរយៈពេលទូទាត់បច្ចុប្បន្ន។

**ខ្ញុំកំពុងដាច់ការភ្ជាប់អ៊ីនធឺណិត តើខ្ញុំត្រូវធ្វើដូចម្តេច?**
ដៅពេលព្យាយាមចូលកម្មវិធី OR PTC DCI Mobile App អ្នកអាចទទួលសារកំហុសថា “Please check your Internet Connection (សូមពិនិត្យសេវាអ៊ីនធឺណិតរបស់អ្នក)”

Click Confirm on the alert:



ប្រសិនបើករណីនេះកើតឡើង
នោះការចុះឈ្មោះឧបករណ៍របស់អ្នកមិនអាចដំណើរការបានឡើយ។
សូមទាក់ទងទៅការិយាល័យក្នុងមូលដ្ឋានរបស់អ្នកដើម្បីស្នើសុំជំនួយ។ ទន្ទឹមនឹងនេះ
អ្នកត្រូវភ្ជាប់ជាមួយអ៊ីនធឺណិតដើម្បីចូលកម្មវិធី OR PTC DCI Mobile App។

***សូមចាំថា៖*** ឧបករណ៍មួយអាចចុះឈ្មោះសម្រាប់តែអ្នកប្រើប្រាស់ម្នាក់ប៉ុណ្ណោះ។ ប្រសិនបើអ្នកដទៃចូលកម្មវិធី OR PTC DCI នៅលើឧបករណ៍របស់អ្នក ឧបករណ៍នោះអាចចុះឈ្មោះសម្រាប់អ្នកប្រើប្រាស់នោះនៅក្នុងកម្មវិធី Mobile App Offline។

## ខ្ញុំត្រូវការជំនួយបន្ថែម!

សម្រាប់ជំនួយបន្ថែមអំពីរបៀបប្រើប្រាស់បណ្តាញ Mobile App Offline
សូមទាក់ទងផ្នែកផ្តល់ជំនួយ DCI Help Desk តាមរយៈលេខ 1-855-565-0155 ឬអ៊ីមែល
ORPTCSupport@dcisoftware.com។

សម្រាប់ជំនួយលើបញ្ហាចុះឈ្មោះឧបករណ៍ និងកំហុសភ្ជាប់អ៊ីនធឺណិត
សូមទាក់ទងទៅការិយាល័យក្នុងមូលដ្ឋានរបស់អ្នក ឬអ៊ីមែល
PTC.Support@dhsoha.state.or.us។